Australian Government

TAX CUTS / 1 JULY 2024

# ការកាត់បន្ថយពន្ធសម្រាប់អ្នកបង់ពន្ធគ្រប់រូប



**នៅទូទាំងប្រទេសអូស្ត្រាលី ពលរដ្ឋទាំងអស់ទទួលកំពុងរងនូវសម្ពាធនៃការចំណាយលើការរស់នៅ។ ហេតុដូច្នេះហើយដែលរដ្ឋាភិបាលអូស្ត្រាលីបានធ្វើការកែប្រែអត្រាពន្ធលើប្រាក់ចំណូល និងកម្រិតបង់ពន្ធរបស់បុគ្គលម្នាក់ៗ។ ចាប់ពីថ្ងៃទី 1 ខែកក្កដា ឆ្នាំ2024 ពលរដ្ឋអូស្ត្រាលីគ្រប់រូបនឹងទទួលបានការកាត់បន្ថយពន្ធ។**

## តើការកាត់បន្ថយពន្ធគឺជាអ្វី?

ការកាត់បន្ថយពន្ធ កាត់បន្ថយចំនួនពន្ធលើប្រាក់ចំណូលដែលអ្នកត្រូវបង់។

## តើការកាត់បន្ថយពន្ធមានន័យយ៉ាងដូចម្តេចចំពោះអ្នក?

សម្រាប់អ្នកបង់ពន្ធជាច្រើន នេះមានន័យថាអ្នកបង់ពន្ធតិចជាងមុននៅថ្ងៃបើកបៀវត្សរ៍ម្តងៗ និងទុកប្រាក់ដែលអ្នករកបានកាន់តែច្រើន។ សម្រាប់អ្នកបង់ពន្ធផ្សេងទៀត អ្នកនឹងទទួលបានការកាត់បន្ថយពន្ធ នៅពេលអ្នកបានដាក់ និងដំណើរការប្រកាសពន្ធលើប្រាក់ចំណូលនៅចុងឆ្នាំហិរញ្ញវត្ថុ 2024-2025។

អ្នកអាចប៉ាន់ស្មានការកាត់បន្ថយពន្ធប្រចាំឆ្នាំរបស់អ្នកដោយប្រើម៉ាស៊ីនគិតលេខការកាត់បន្ថយពន្ធនៅ taxcuts.gov.au/khmer

## ចុះប្រសិនបើខ្ញុំជាម្ចាស់អាជីវកម្ម?

ប្រសិនបើអ្នកបើកអាជីវកម្មហើយមានជួលបុគ្គលិក អ្នកត្រូវធានាថាអ្នកត្រូវកាត់ទុកពន្ធតាមចំនួនប្រាក់ចំណូលដែលរកបាន (PAYG)ឲ្យបានត្រឹមត្រូវពីបៀវត្សរ៍របស់និយោជិកម្នាក់ៗរៀងរាល់ថ្ងៃបើកបៀវត្សរ៍ម្តងៗ។

វិធីងាយស្រួលបំផុតដើម្បីធ្វើដូចនេះគឺត្រូវផ្ទៀងផ្ទាត់ថាតើកម្មវិធីបើកបៀវត្សរ៍របស់អ្នកប្រើអត្រាកាត់ទុកពន្ធថ្មីចាប់ពីថ្ងៃទី 1 ខែកក្កដា ឆ្នាំ2024ឬអត់។ ប្រសិនបើអ្នកមិនប្រើកម្មវិធីបើកបៀវត្សរ៍ទេ អ្នកក៏អាចផ្ទៀងផ្ទាត់តារាងកាត់ពន្ធ PAYG ឲ្យបានត្រឹមត្រូវផងដែរ។

**ចូរស្កេនកូដ QR ខាងក្រោម ដើម្បីស្វែងរកព័ត៌មានបន្ថែម តាមភាសាដែលអ្នកនិយមចូលចិត្ត។**

**ព័ត៌មានជាច្រើនភាសា**

គណនាការកាត់ពន្ធរបស់អ្នកនៅតាមគេហទំព័រ taxcuts.gov.au/khmer